ក

មាតិកា

I-ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

១-ព្រះរាជក្រម

០៣-៧-២០០៩ -ព្រះរាជក្រម នស/រកម/០៧០៩/០១០ ស្តីពីការប្រកាសឱ្យប្រើ ច្បាប់ស្តីពីកិច្ចការពារ និង លើកកំពស់សិទ្ធិជនពិការ ៥០២៤

២-ព្រះរាជក្រឹត្យ

១៦-៦-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៦០៩/៦៤៨ ស្តីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះឯកឧត្តម,លោកឧកញ៉ា,អស់លោក និង លោកស្រី ចំនួន ៥៧ រូប ៥០៤៤

១១-៧-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៧០៩/៧២៧ ស្តីពីការតម្លើងថ្នាក់ក្នុងឋានន្តរស័ក្តិ ឧត្តមមន្ត្រីនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល របស់ក្រសួង ស្ថាប័ន គិតចាប់ពីថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០០៩ ចំនួន ៣៧ រូប ៥០៤៨

១១-៧-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៧០៩/៧២៨ ស្តីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះអស់លោក ចំនួន ១១ រូប ៥០៥១

១១-៧-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៧០៩/៧២៩ ស្តីពីការប្រោសព្រះរាជទាន គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ជូនចំពោះ អស់លោក ចំនួន ០៣ រូប ៥០៥២

II-រាជរដ្ឋាភិបាល

១-អនុក្រឹត្យ

២៨-៥-២០០៩ -អនុក្រឹត្យលេខ ៧៧៥ អនក្រ.បក ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សា ស្រុកស្នួល នៃខេត្តក្រចេះ ៥០៥៣

២៨-៥-២០០៩ -អនុក្រឹត្យលេខ ៧៧៦ អនក្រ.បក ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សា ស្រុកឆ្លូង នៃខេត្តក្រចេះ ៥០៥៥

២៨-៥-២០០៩ -អនុក្រឹត្យលេខ ៧៧៧ អនក្រ.បក ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សា ក្រុងក្រចេះ នៃខេត្តក្រចេះ ៥០៥៧

២៨-៥-២០០៩ -អនុក្រឹត្យលេខ ៧៧៨ អនក្រ.បក ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សា ស្រុកព្រែកប្រសព្វ នៃខេត្តក្រចេះ ៥០៥៩

២៨-៥-២០០៩ -អនុក្រឹត្យលេខ ៧៧៩ អនក្រ.បក ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សា ស្រុកចិត្របូរី នៃខេត្តក្រចេះ ៥០៦១

២៨-៥-២០០៩ -អនុក្រឹត្យលេខ ៧៨០ អនក្រ.តត ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សា ស្រុកសំបូរ នៃខេត្តក្រចេះ ៥០៦៣
២៨-៥-២០០៩ -អនុក្រឹត្យលេខ ៨០៦ អនក្រ.តត ស្តីពីការតែងតាំងមុខតំណែងមន្ត្រីរាជការ ៥០៦៥
១០-៦-២០០៩ -អនុក្រឹត្យលេខ ១០៣១ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៥០៦៧
១០-៦-២០០៩ -អនុក្រឹត្យលេខ ១០៣២ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៥០៦៩
១០-៦-២០០៩ -អនុក្រឹត្យលេខ ១០៣៣ អនក្រ.តត ស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាភិបាលនៃ វិទ្យាស្ថានជាតិ ពហុបច្ចេកទេសកម្ពុជា ៥០៧៤
១០-៦-២០០៩ -អនុក្រឹត្យលេខ ១០៣៤ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៥០៧៦
១០-៦-២០០៩ -អនុក្រឹត្យលេខ ១០៣៥ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៥០៧៧
១១-៦-២០០៩ -អនុក្រឹត្យលេខ ១០៣៦ អនក្រ.តត ស្តីពីការជូនមេដាយសុវត្ថារា ៥០៧៨
១១-៦-២០០៩ -អនុក្រឹត្យលេខ ១០៣៧ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៥០៧៩
១១-៦-២០០៩ -អនុក្រឹត្យលេខ ១០៣៨ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៥០៨០
១១-៦-២០០៩ -អនុក្រឹត្យលេខ ១០៣៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥០៨១
១១-៦-២០០៩ -អនុក្រឹត្យលេខ ១០៤០ អនក្រ.តត ស្តីពីការតម្លើងឋានន្តរស័ក្តិ ជូនមន្ត្រីនគរបាលជាតិ ៥០៨៣
១១-៦-២០០៩ -អនុក្រឹត្យលេខ ១០៤១ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ និង មេដាយការងារ ៥០៨៤
១១-៦-២០០៩ -អនុក្រឹត្យលេខ ១០៤២ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ៥០៨៥
១១-៦-២០០៩ -អនុក្រឹត្យលេខ ១០៤៣ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៥០៨៦
១២-៦-២០០៩ -អនុក្រឹត្យលេខ ១០៤៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥០៨៧
១២-៦-២០០៩ -អនុក្រឹត្យលេខ ១០៤៥ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ៥០៨៨
១២-៦-២០០៩ -អនុក្រឹត្យលេខ ១០៤៦ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ៥០៨៩
១២-៦-២០០៩ -អនុក្រឹត្យលេខ ១០៤៧ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៥០៩០
១២-៦-២០០៩ -អនុក្រឹត្យលេខ ១០៤៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥០៩២

២_សេចក្តីសំរេច

០៨-៧-២០០៩ -សេចក្តីសំរេចលេខ ៤២ សសរ ស្តីពីការបន្ថែមសមាជិកគណៈកម្មការអន្តរក្រសួង ដើម្បី សម្រួលការធ្វើដំណើរ និង ដឹកជញ្ជូនភ្ញៀវទេសចរ និង អ្នកដំណើរនៅតំបន់ច្រកទ្វារព្រំដែន អន្តរជាតិប៉ោយប៉ែត និង ច្រកទ្វារព្រំដែនអន្តរជាតិផ្សេងៗទៀត ៥០៩៣
០៩-៧-២០០៩ -សេចក្តីសំរេចលេខ ៤៣ សសរ ស្តីពីការផ្ទេរសិទ្ធការងាររបស់រាជរដ្ឋាភិបាល ៥០៩៥

III-ការិយាល័យបណ្ដាក្រសួង

១- ទីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

០៧-៧-២០០៩ -ប្រកាសលេខ ៥០១ ឧរថ.កឧ.ប្រក ស្ដីពីការអនុញ្ញាតឱ្យក្រុមហ៊ុន អាយ អីភែរីល អិលធីឌី បង្កើតរោងចក្រ "ផលិតសម្លៀកបំពាក់" ៥០៩៦

០៧-៧-២០០៩ -ប្រកាសលេខ ៥០២ ឧរថ.កឧ.ប្រក ស្ដីពីការអនុញ្ញាតឱ្យក្រុមហ៊ុន ដាយរិក រូត ខូ អិលធីឌី បង្កើតរោងចក្រ "ផលិតសម្លៀកបំពាក់" ៥១០១

២- ទីស្ដីការរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

០៦-៧-២០០៩ -ប្រកាសលេខ ៣៥៣ ប្រក.កសក.ប ស្ដីពីការបង្កើតការិយាល័យកសិកម្មក្រុងបាវិត ចំណុះមន្ទីរកសិកម្ម ខេត្តស្វាយរៀង ៥១០៦

៣-ទីស្ដីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

២៤-១០-២០០៨ -លិខិតបញ្ជាក់លេខ ៥៧៣៨ ពណ.ចបព ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មនិង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឡាមស៍ & ប្រាឌើរ (ខេមបូឌា) ខូ អិលធីឌី** ៥១០៨

២៤-១០-២០០៨ -លិខិតបញ្ជាក់លេខ ៥៧៤០ ពណ.ចបព ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មនិង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **គ្រេឌីច ហៅស៍ (ខេមបូឌា)** ៥១១០

២៤-១០-២០០៨ -លិខិតបញ្ជាក់លេខ ៥៧៤៤ ពណ.ចបព ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មនិង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេចឌីរ៉ូ ស៊ីនស៊ីច** ៥១១២

២៤-១០-២០០៨ -លិខិតបញ្ជាក់លេខ ៥៧៤៥ ពណ.ចបព ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មនិង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេមបូឌាន អេ អេស អេ ហ្វាយណែន លីមីធីត** ៥១១៤

២៤-១០-២០០៨ -លិខិតបញ្ជាក់លេខ ៥៧៤៧ ពណ.ចបព ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មនិង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេស៊ា យូនៀន ខនស្រ្ដាក់សិន លីមីធីត** ៥១១៦

២៤-១០-២០០៨ -លិខិតបញ្ជាក់លេខ ៥៧៥៧ ពណ.ចបព ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មនិង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេអេសអេចប៊ី ស្ទីល** ៥១១៨

២៧-១០-២០០៨ -លិខិតបញ្ជាក់លេខ ៥៧៥៨ ពណ.ចបព ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មនិង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេម-ប៊ីស គ្រុប** ៥១២០

២៧-១០-២០០៨ -លិខិតបញ្ជាក់លេខ ៥៧៥៩ ពណ.ចបព ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មនិង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សុខ ណាច ហ្វេមីលី អ៊ិនធើណេសិនណល** ៥១២២

២៤-១០-២០០៨ -លិខិតបញ្ជាក់លេខ ៥៧៦០ ពណ.ចបព ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មនិង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អាយ អាយ អេស ខមភេនី** ៥១២៤

២៧-១០-២០០៨ -លិខិតបញ្ជាក់លេខ ៥៧៦១ ពណ.ចបព ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មនិង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **បាគខូដាគ គ្លូប៊ល ឡូជីស្ទិគ (ខេមបូឌា)** ៥១២៦

ព្រះរាជក្រម

នស/រកម/០៧០៩/០១០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៩ នាសម័យប្រជុំរដ្ឋសភា លើកទី២ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ នាសម័យប្រជុំវិសាមញ្ញ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ ៖

ច្បាប់

ស្តីពី

កិច្ចការពារ និង

លើកកម្ពស់សិទ្ធិជនពិការ

3/21

ជំពូកទី ១
បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

ច្បាប់នេះមានគោលដៅការពារ និងលើកកម្ពស់សិទ្ធិជនពិការក្នុងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ២.-

ច្បាប់នេះ មានគោលបំណង ដូចតទៅ :

-ការពារសិទ្ធិ និងសេរីភាពរបស់ជនពិការ

-ការពារផលប្រយោជន៍ជនពិការ

-ទប់ស្កាត់ កាត់បន្ថយ និងលុបបំបាត់ការរើសអើងជនពិការ

-ស្តារកាយសម្បទា សតិបញ្ញា និងវិជ្ជាជីវៈ ដើម្បីធានាលទ្ធភាពក្នុងការចូលរួមដ៏ពេញលេញ និងដោយស្មើភាពនៃជនពិការក្នុងសកម្មភាពនានារបស់សង្គម ។

មាត្រា ៣.-

ច្បាប់នេះ មានវិសាលភាពអនុវត្តចំពោះជនពិការ និងសកម្មភាពទាំងឡាយណាដែលទាក់ទងនឹងជនពិការនៅព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៤.-

វាក្យស័ព្ទសំខាន់ៗ ដែលប្រើនៅក្នុងច្បាប់នេះ មានន័យដូចតទៅ :

-**ជនពិការ** សំដៅដល់ជនទាំងឡាយណាដែលខ្វះខាត បាត់បង់ ខូចខាតសរីរាង្គណាមួយ ឬ សតិបញ្ញា បណ្តាលឱ្យមានការរំខានដល់ជីវភាពរស់នៅ ឬ សកម្មភាពនានាប្រចាំថ្ងៃ ដូចជាជនពិការរាងកាយ ពិការភ្នែក ពិការក្នុងការស្តាប់ ពិការសតិបញ្ញា មនសិការវិកលនិងប្រភេទពិការផ្សេងៗទៀត ដែលនាំឱ្យមានលក្ខណៈមិនប្រក្រតី ។

- **ទីកន្លែងសាធារណៈ** សំដៅដល់បរិវេណ ទីតាំង អគារនិងមធ្យោបាយដឹកជញ្ជូននានា ដែលជាកម្មសិទ្ធិរដ្ឋ សាធារណៈ ឬ ឯកជនដែលបើកទូលាយ និងផ្តល់សេវាដល់សាធារណជនទូទៅ ជាអាទិ៍ : ក្រសួង ស្ថាប័ន មន្ទីរ ផ្លូវថ្នល់ កន្លែងលំហែកាយ មជ្ឈមណ្ឌលវប្បធម៌ កន្លែងលេងកីឡា កន្លែងកំសាន្ត គ្រឹះស្ថានអប់រំ សណ្ឋាគារ មន្ទីរពេទ្យ មណ្ឌលសុខភាព អាហារដ្ឋាន ប្រព័ន្ធដឹកជញ្ជូន ។

- **គ្រឹះស្ថានសិក្សាសាធារណៈ** សំដៅដល់សាលាសាធារណៈ ដែលបានធ្វើការអប់រំ បណ្តុះបណ្តាលសិស្សគ្រប់វ័យ ។ គ្រឹះស្ថានសិក្សាសាធារណៈ រាប់បញ្ចូលចាប់ពីកម្រិតមត្តេយ្យសិក្សាឡើងទៅ ។

- **គ្រឹះស្ថានសិក្សាឯកជន** សំដៅដល់សាលាឯកជន ឬ អង្គការទាំងឡាយណាដែលបានទទួលការអនុញ្ញាតឱ្យបង្កើត សម្រាប់ធ្វើការអប់រំបណ្តុះបណ្តាលសិស្សគ្រប់វ័យ ។

ជំពូកទី ២
ក្រុមប្រឹក្សាសកម្មភាពជនពិការ និងរដ្ឋបាលសិទ្ធិជនពិការ

មាត្រា ៥.-

ត្រូវបានបង្កើតក្រុមប្រឹក្សាសកម្មភាពជនពិការ មានអក្សរកាត់ថា (**ក.ស.ជ**) ជាយន្តការសម្របសម្រួលថ្នាក់ជាតិ និងពិគ្រោះយោបល់លើបញ្ហាពិការភាព ។

មាត្រា ៦.-

ក្រុមប្រឹក្សាសកម្មភាពជនពិការ មានភារកិច្ចដូចខាងក្រោម :

-ផ្តល់ការពិគ្រោះយោបល់ជំនាញលើបញ្ហាពិការភាព និងការស្តារលទ្ធភាពពលកម្ម

-ជួយក្រសួង ស្ថាប័ន និងអង្គការពាក់ព័ន្ធ ក្នុងការរៀបចំគោលនយោបាយ ផែនការជាតិ និងយុទ្ធសាស្ត្រដែលមានការពាក់ព័ន្ធទៅនឹងពិការភាព និងការស្តារលទ្ធភាព

-ជម្រុញការអនុវត្តគោលនយោបាយ ច្បាប់ និងបទបញ្ញាផ្សេងៗពាក់ព័ន្ធនឹងបញ្ហាពិការភាព និងការស្តារលទ្ធភាពពលកម្ម

-លើកសំណើកែសម្រួល បំពេញបន្ថែម ធ្វើវិសោធនកម្មគោលនយោបាយ ច្បាប់ និង បទបញ្ញាផ្សេងៗ ពាក់ព័ន្ធនឹងបញ្ហាពិការភាព

-តាមដាន វាយតម្លៃការអនុវត្តគោលនយោបាយ ផែនការជាតិ ច្បាប់ និងបទបញ្ញាផ្សេងៗពាក់ព័ន្ធនឹងបញ្ហាពិការភាព

-ទំនាក់ទំនងជាមួយសហគមន៍ជាតិ-អន្តរជាតិ ដើម្បីផ្លាស់ប្តូរបទពិសោធន៍ កៀរគរប្រភពធនធានទាំងក្នុង និងក្រៅប្រទេស ។

មាត្រា ៧.-

ក្រុមប្រឹក្សាសកម្មភាពជនពិការរួមមាន :

-រដ្ឋមន្ត្រីទទួលបន្ទុកវិស័យសង្គមកិច្ច ឬ តំណាង ជាប្រធាន

-តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ

-តំណាងអង្គការជនពិការ

-តំណាងអង្គការ និយោជក និងអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើសកម្មភាពជួយដល់ជនពិការ ។

ការរៀបចំសមាសភាព និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាសកម្មភាពជនពិការ ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ៨.-

ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ត្រូវបង្កើតរដ្ឋបាលសិទ្ធិជនពិការដែលជាអង្គភាពចំណុះនាយកដ្ឋានស្តារលទ្ធភាពពលកម្ម ។

មាត្រា ៩.-

ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ដោយសហការជាមួយក្រសួង ស្ថាប័ន និងអង្គការពាក់ព័ន្ធ មានភារកិច្ចរៀបចំទិវាជនពិការកម្ពុជា និងទិវាកីឡាជនពិការកម្ពុជា ក្នុងគោល

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

បំណងបំផុសការយល់ដឹងជាសាធារណៈអំពីសុខុមាលភាពនៃជនពិការ និងលើកទឹកចិត្តជនពិការ ដើម្បីចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងសកម្មភាពផ្សេងៗទៀត ។

ទិវាជនពិការកម្ពុជា និងទិវាកីឡាជនពិការកម្ពុជា ត្រូវប្រារព្ធធ្វើរួមគ្នាជាមួយទិវាជនពិការអន្តរជាតិ ថ្ងៃទី ៣ ខែ ធ្នូ ជារៀងរាល់ឆ្នាំ ។

ជំពូកទី ៣
ជីវភាពរស់នៅ

មាត្រា ១០.-

រដ្ឋត្រូវយកចិត្តទុកដាក់ ជួយលើកតម្កើងជីវភាពរស់នៅរបស់ជនពិការឱ្យបានសមរម្យស្របតាមស្ថានភាពសេដ្ឋកិច្ចជាតិ ។

មាត្រា ១១.-

រដ្ឋត្រូវមានវិធានការចាំបាច់នានា ដើម្បីបំផុសលើកទឹកចិត្តពលរដ្ឋ សប្បុរសជនផ្នែកឯកជន និងអង្គការសង្គម ឱ្យចូលរួមជួយឧបត្ថម្ភដល់ជនពិការ ។

មាត្រា ១២.-

រដ្ឋត្រូវរៀបចំគោលនយោបាយផ្គត់ផ្គង់ និងមានថវិកាប្រចាំឆ្នាំ ដើម្បីជួយឧបត្ថម្ភដល់ជនពិការ ដែល :

-មានកម្រិតពិការភាពធ្ងន់ធ្ងរ និងក្រីក្របំផុត និងគ្មានទីពឹង ឬ

-ចាស់ជរា និងក្រីក្របំផុត និងគ្មានទីពឹង ឬ

-មានគ្រោះថ្នាក់ធ្ងន់ធ្ងរ និងក្រីក្របំផុត និងគ្មានទីពឹង ។

រដ្ឋត្រូវមានថវិកាប្រចាំឆ្នាំ ដើម្បីធ្វើសមាហរណកម្មជនពិការទៅក្នុងសហគមន៍ ។

មាត្រា ១៣.-

មាតា បិតា និងអ្នកអាណាព្យាបាលជនពិការត្រូវ :

-ការពារសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ជនពិការ

-យកចិត្តទុកដាក់បីបាច់ថែរក្សាជនពិការឱ្យបានល្អ

-លើកទឹកចិត្ត និងជួយជនពិការឱ្យមានក្តីសង្ឃឹមក្នុងជីវិត ។

ការមិនយកចិត្តទុកដាក់ថែទាំ ការគេងប្រវញ្ច និងការបោះបង់ជនពិការ ត្រូវហាមឃាត់ ។

ជំពូកទី ៤
ការស្តារកាយសម្បទា និងសតិបញ្ញា ការថែទាំសុខភាព និងការបង្ការ

មាត្រា ១៤.-

រដ្ឋត្រូវរៀបចំកម្មវិធីស្តារកាយសម្បទា និងសតិបញ្ញា សំដៅជួយដល់ជនពិការឱ្យអាចបំពេញមុខងារ និងប្រើប្រាស់សមត្ថភាព ទេពកោសល្យ ក្នុងជីវភាពសង្គម ។

មាត្រា ១៥.-

រដ្ឋត្រូវបង្កើត និងលើកទឹកចិត្តដល់អង្គការសង្គម និងផ្នែកឯកជនឱ្យបង្កើតជាអាទិ៍ :

-មជ្ឈមណ្ឌលស្តារកាយសម្បទា និងសតិបញ្ញា

-សាលាសម្រាប់បណ្តុះបណ្តាល អ្នកបច្ចេកទេសផលិត ឧបករណ៍ទ្រទ្រង់រាងកាយ

-មជ្ឈមណ្ឌលផលិតគ្រឿងផ្សំ ឧបករណ៍ទ្រទ្រង់រាងកាយ ដើម្បីធានាសេចក្តីត្រូវការនៃមជ្ឈមណ្ឌលស្តារកាយសម្បទានានា ក្នុងការផ្តល់ឧបករណ៍ទ្រទ្រង់រាងកាយដល់ជនពិការ ។

ការបង្កើតមជ្ឈមណ្ឌលស្តារកាយសម្បទា សតិបញ្ញា និងមជ្ឈមណ្ឌលផលិតគ្រឿងផ្សំ ឧបករណ៍ទ្រទ្រង់រាងកាយ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកវិស័យសង្គម-

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

មាត្រា ១៦.-

ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច សហការជាមួយក្រសួងទទួលបន្ទុកវិស័យសុខាភិបាល ត្រូវ :

-រៀបចំកម្មវិធីបណ្តុះបណ្តាលបច្ចេកទេសព្យាបាលដោយចលនា និងព្យាបាលសតិបញ្ញា នៅតាមសាលាបច្ចេកទេសថែទាំវេជ្ជសាស្ត្រនានា ហើយបញ្ចូលផ្នែកនេះឱ្យមានគ្រប់មន្ទីរពេទ្យ ដើម្បីព្យាបាលអ្នកជំងឺកុំឱ្យធ្លាក់ខ្លួនពិការ

-ជួយបណ្តុះបណ្តាលគ្រួសារ ដែលមានសមាជិកពិការ ជនពិការ និងអ្នកស្ម័គ្រចិត្ត អំពីវិធីថែទាំ និងបច្ចេកទេសស្តារលទ្ធភាពពលកម្ម តាមប្រភេទពិការនីមួយៗ ដើម្បីឱ្យគ្រួសារដែលមានសមាជិកពិការ ជនពិការមានលទ្ធភាពស្តារកាយសម្បទា និងសតិបញ្ញាជនពិការ

-ពង្រីកសេវាស្តារលទ្ធភាពពលកម្ម តាមសហគមន៍ សេវាពិគ្រោះយោបល់ព្យាបាលជំងឺផ្លូវចិត្ត និងសតិបញ្ញាខ្សោយ ។

មាត្រា ១៧.-

រដ្ឋត្រូវបង្កើតកម្មវិធីបង្ការពិការភាព ដល់ពលរដ្ឋគ្រប់រូបតាមរយៈ :

-ការថែទាំសុខភាពក្នុងពេលមានគភ៌

-ការតាមដាន និងការវិនិច្ឆ័យរោគ ដែលនាំឱ្យមានពិការភាព ទាន់ពេលវេលា

-ការផ្តល់ថ្នាំបង្ការជំងឺ ដែលនាំឱ្យមានពិការភាព

-ការផ្តល់អាហារទ្រទ្រង់រាងកាយ

-ការអប់រំអំពីមូលហេតុដែលនាំឱ្យមានពិការភាព

-ការព្យាបាលតាមវិធីវេជ្ជសាស្ត្រ និងការអប់រំកាយសម្បទាឡើងវិញឱ្យទាន់ពេលវេលា ។

មាត្រា ១៨.-

ក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវបង្កលក្ខណៈឱ្យជនពិការបានចូលរួមរៀបចំរាល់គម្រោងអភិវឌ្ឍ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលប៉ះពាល់ដល់ផលប្រយោជន៍ជនពិការ។ ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវដាក់បញ្ចូលសេចក្តីត្រូវការរបស់ជនពិការទៅក្នុងកម្មវិធីអភិវឌ្ឍន៍នានា ។

មាត្រា ១៩.-

គោលនយោបាយជួយឧបត្ថម្ភ សេវាពិនិត្យថែទាំសុខភាព ព្យាបាលនិងស្តារលទ្ធភាពពលកម្មកាយសម្បទា ដល់ជនពិការដែលមានពិការភាពធ្ងន់ធ្ងរ ឬ ក្រីក្របំផុតគ្មានទីពឹង ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ២០.-

លក្ខណវិនិច្ឆ័យប្រភេទ និងកម្រិតនៃពិការភាព ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីទទួលបន្ទុកវិស័យសង្គមកិច្ច និងរដ្ឋមន្ត្រីទទួលបន្ទុកវិស័យសុខាភិបាល ។

ការកំណត់លក្ខណវិនិច្ឆ័យ និងកម្រិតនៃពិការភាពរបស់យោធិន ត្រូវមានការចូលរួមពីក្រសួងទទួលបន្ទុកវិស័យការពារជាតិ ។

ជំពូកទី ៥
ការចេញចូលទីកន្លែងសាធារណៈ

មាត្រា ២១.-

រាល់ទីកន្លែងសាធារណៈ ត្រូវរៀបចំឱ្យមានលក្ខណៈងាយស្រួលចេញចូលសម្រាប់ជនពិការគ្រប់ប្រភេទ ដូចជាការធ្វើជម្រាល ការបំពាក់ឧបករណ៍ផ្ទាក់ដៃនៅតាមបន្ទប់ទឹក ការដាក់ផ្លាកសញ្ញានានា ។

មាត្រា ២២.-

ក្រសួងមានសមត្ថកិច្ចដែលផ្តល់លិខិតអនុញ្ញាតលើគម្រោងសាងសង់ ការសាងសង់ និងត្រួតពិនិត្យសំណង់ ទីកន្លែងសាធារណៈ ត្រូវធានាលក្ខណៈងាយស្រួលចេញចូលរបស់ជនពិការ ដូចមានចែងក្នុងមាត្រា ២១ នៃច្បាប់នេះ ។

មាត្រា ២៣.-

ការរៀបចំលក្ខណៈងាយស្រួលចេញចូល នៅទីកន្លែងសាធារណៈ ឬ លើមធ្យោបាយ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ដឹកជញ្ជូនផ្សេងៗ សម្រាប់ជនពិការ ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីទទួលបន្ទុកវិស័យសង្គមកិច្ច និងក្រសួង ស្ថាប័នពាក់ព័ន្ធ ។

មាត្រា ២៤.-

ជនពិការមានសិទ្ធិទទួលប័ណ្ណបើកបរយានយន្ត ។ សមត្ថភាពបើកបរយានយន្តនៃជនពិការ ព្រមទាំងប្រភេទយានយន្តសម្រាប់ជនពិការ ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីទទួលបន្ទុកវិស័យសាធារណការ និងដឹកជញ្ជូន និងរដ្ឋមន្ត្រីទទួលបន្ទុកវិស័យសុខាភិបាល ។

មាត្រា ២៥.-

ក្រសួងទទួលបន្ទុកវិស័យសាធារណការ និងដឹកជញ្ជូន ត្រូវចេញប័ណ្ណសម្គាល់យានយន្ត និងប័ណ្ណបើកបរពិសេសដល់ជនពិការ ។ ជនពិការដែលបើកបរយានយន្ត អាចដាក់បង្ហាញប័ណ្ណបើកបរ ឬ ប័ណ្ណសម្គាល់យានយន្ត នៅជាប់នឹងយានយន្តរបស់ខ្លួន ដើម្បីឱ្យអ្នកដទៃមើលឃើញ ។

ជនពិការត្រូវដាក់បង្ហាញប័ណ្ណនេះនៅជាប់នឹងយានយន្ត នៅពេលចតលើចំណតសម្រាប់ជនពិការ ។

ការក្លែងបន្លំ ឬ ការបំភាន់ ដើម្បីទទួលបានសិទ្ធិ និងអាទិភាពនេះ ត្រូវហាមឃាត់ ។

មាត្រា ២៦.-

រាល់ទីកន្លែងសាធារណៈ ដែលមានចំណតយានយន្ត ត្រូវរៀបចំឱ្យមានចំណតយានយន្តពិសេសសម្រាប់ជនពិការ ។

រាល់ទីកន្លែងសាធារណៈ ដែលមានបន្ទប់អនាម័យ ត្រូវរៀបចំឱ្យមានបន្ទប់អនាម័យសម្រាប់ជនពិការ ។

ការរៀបចំចំណតយានយន្តសម្រាប់ជនពិការ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកវិស័យសាធារណការ និងដឹកជញ្ជូន ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL ·

ជំពូកទី ៦
ការអប់រំ

មាត្រា ២៧.–

សិស្ស-និស្សិតពិការគ្រប់រូប មានសិទ្ធិចូលសិក្សាក្នុងគ្រឹះស្ថានសិក្សាសាធារណៈ និង ឯកជន និងមានសិទ្ធិទទួលអាហារូបករណ៍ដូចសិស្ស-និស្សិតដទៃទៀតដែរ លើកលែងតែមានបញ្ញត្តិផ្ទុយពីនេះ ។

មាត្រា ២៨.–

រដ្ឋត្រូវបង្កើតគោលនយោបាយ និងយុទ្ធសាស្ត្រជាតិ សម្រាប់អប់រំសិស្ស-និស្សិតពិការ ដូចជា :

-ការជំរុញធ្វើសមាហរណកម្ម សិស្ស-និស្សិតពិការ ទៅក្នុងថ្នាក់រៀនចម្រុះតាមដែលអាចធ្វើទៅបាន

-ការបង្កើតថ្នាក់រៀនពិសេស សម្រាប់ឆ្លើយតបនឹងសេចក្តីត្រូវការនៃសិស្ស-និស្សិតពិការ ។

មាត្រា ២៩.–

ក្រសួងទទួលបន្ទុកវិស័យអប់រំ ត្រូវរៀបចំកម្មវិធីសម្រាប់គ្រឹះស្ថានសិក្សានានាក្នុងការសម្របសម្រួលដល់សិស្ស-និស្សិតពិការនូវផ្នែកមួយចំនួន ដូចជា :

-អគារ បន្ទប់ និងកន្លែងសិក្សា

-ភាសាសញ្ញា និងអក្សរស្ទាប

-បច្ចេកទេសអប់រំ និងគរុកោសល្យ ស្របទៅតាមប្រភេទពិការភាព

-សម្ភារៈសិក្សា ឬ ឧបករណ៍ផ្សេងៗ សម្រាប់ជំនួយដល់សិស្ស-និស្សិតពិការ

-សម្ភារៈឧបទេសសម្រាប់គ្រូបង្រៀន ឬ សាស្ត្រាចារ្យ និងផ្នែកផ្សេងៗទៀត តាមតម្រូវការជាក់ស្តែងរបស់សិស្ស-និស្សិតពិការម្នាក់ៗ ។

មាត្រា ៣០.-

ក្រសួងទទួលបន្ទុកវិស័យអប់រំ ត្រូវយកចិត្តទុកដាក់ជាពិសេសដល់សេចក្តីត្រូវការផ្នែកអប់រំរបស់សិស្ស-និស្សិតពិការ ។

សិស្ស-និស្សិតពិការក្នុងគ្រួសារក្រីក្រ ឬ ជាយោធិនពិការ ត្រូវបានទទួលដោយឥតគិតថ្លៃនូវការចូលសិក្សានៅតាមគ្រឹះស្ថានសិក្សាសាធារណៈគ្រប់កម្រិតសិក្សា និងសៀវភៅសិក្សាព្រមទាំងសម្ភារៈសិក្សា ។

គ្រឹះស្ថានសិក្សាឯកជន ត្រូវមានគោលការណ៍ពិសេសចុះថ្លៃការសិក្សា សៀវភៅសិក្សា និងសម្ភារៈសិក្សាសម្រាប់សិស្ស-និស្សិតពិការ ឬ ជាយោធិនពិការ ។

ការកំណត់ការចុះថ្លៃការសិក្សា និងសម្ភារៈសិក្សា ត្រូវចែងដោយប្រកាសរួមរបស់រដ្ឋមន្ត្រីទទួលបន្ទុកវិស័យសង្គមកិច្ច និងរដ្ឋមន្ត្រីទទួលបន្ទុកវិស័យអប់រំ ។

មាត្រា ៣១.-

ក្រសួងទទួលបន្ទុកវិស័យអប់រំ ត្រូវដាក់បញ្ចូលក្នុងកម្មវិធីបញ្ជ្រាបការសិក្សា ជាអាទិ៍ : អំពីមូលហេតុនៃពិការភាពវិធីបង្ការ និងតម្លៃរបស់ជនពិការ ។

ក្រសួងទទួលបន្ទុកវិស័យអប់រំ ត្រូវមានកម្មវិធីគរុកោសល្យអំពីពិការភាពសម្រាប់បំពាក់បំប៉នគ្រូ និងសាស្ត្រាចារ្យគ្រប់រូបឱ្យយល់ដឹងពីពិការភាព និងវិធីសាស្ត្របង្រៀនសិស្ស-និស្សិតពិការ ។

មាត្រា ៣២.-

ក្រសួងទទួលបន្ទុកវិស័យព័ត៌មាន ត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយនូវការយល់ដឹងជាសាធារណៈអំពីពិការភាពនិងសិទ្ធិជនពិការ ដើម្បីពង្រឹងសាមគ្គីភាព ការយោគយល់ និងការគោរពសិទ្ធិជនពិការ តាមប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ ដោយឥតបង់ថ្លៃ ។

ចំពោះប្រព័ន្ធផ្សព្វផ្សាយឯកជន ត្រូវមានកម្មវិធីផ្សព្វផ្សាយពិសេសចូលរួមយ៉ាងសកម្មក្នុងសកម្មភាពខាងលើ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

1/4k

ksl

ជំពូកទី ៧

ការងារ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ

មាត្រា ៣៣.-

ជនពិការដែលមានលក្ខណសម្បត្តិ និងសមត្ថភាពបំពេញនូវមុខងារ តួនាទី និងការទទួលខុសត្រូវក្នុងមុខតំណែង មានសិទ្ធិចូលបម្រើការងារ ដោយគ្មានការរើសអើងរាប់ទាំងការបម្រើការងារជាមន្ត្រីរាជការ កម្មករ និយោជិត កូនជាង ឬ កម្មសិក្សាការី ។

មាត្រា ៣៤.-

នីតិបុគ្គលដែលជ្រើសរើសកម្មករ និយោជិតធ្វើការ ត្រូវទទួលយកជនពិការដូចមានចែងក្នុងមាត្រា ៣៣ នៃច្បាប់នេះ ឱ្យចូលធ្វើការតាមអត្រាកំណត់សមស្រប ។

អត្រានេះ ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកវិស័យសង្គមកិច្ច រដ្ឋមន្ត្រីទទួលបន្ទុកវិស័យការងារ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

មាត្រា ៣៥.-

ក្រសួង ស្ថាប័នរដ្ឋ ដែលជ្រើសរើសមន្ត្រីរាជការឱ្យចូលធ្វើការងារ ត្រូវជ្រើសរើសជនពិការ ដូចមានចែងក្នុងមាត្រា ៣៣ នៃច្បាប់នេះ ក្នុងអត្រាកំណត់សមស្រប ។

អត្រា និងបែបបទជ្រើសរើស ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ៣៦.-

នីតិបុគ្គលដែលទទួលជនពិការ ឱ្យចូលធ្វើការតាមអត្រាកំណត់សមស្រប ត្រូវធ្វើសេចក្ដីជូនដំណឹងជាទៀងទាត់អំពីចំនួនកម្មករនិយោជិតធ្វើការទាំងអស់ និងកម្មករ និយោជិតជាជនពិការទៅក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច និងក្រសួងទទួលបន្ទុកវិស័យការងារ ។

មាត្រា ៣៧.-

នីតិបុគ្គលដែលមិនអាចបំពេញតាមកាតព្វកិច្ច ដូចមានចែងក្នុងមាត្រា ៣៤ និងមាត្រា ៣៥ នៃច្បាប់នេះ ត្រូវបង់ភាគទានចូលហិបមូលនិធិនៃជនពិការ ។

អត្រានៃការបង់ភាគទាន ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកវិស័យសង្គមកិច្ច រដ្ឋមន្ត្រីទទួលបន្ទុកវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

មាត្រា ៣៨.–

នីតិបុគ្គលត្រូវរៀបចំឱ្យមានការសម្របសម្រួលសមស្រប សម្រាប់ជនពិការ ដែលជាបេក្ខជនដាក់ពាក្យសុំបម្រើការងារ ជាកម្មករ និយោជិត ឬ កូនជាង ឬ កម្មសិក្សាការី លើកលែងតែក្នុងករណីការសម្របសម្រួលនោះ មានបន្ទុកធ្ងន់ធ្ងរហួសហេតុ ។

មាត្រា ៣៩.–

រដ្ឋត្រូវយកចិត្តទុកដាក់បង្កើតស្ថាប័នបណ្តុះបណ្តាលវិជ្ជាជីវៈ សម្រាប់ជនពិការ ។

គ្រឹះស្ថានអប់រំ បណ្តុះបណ្តាល បច្ចេកទេស និងវិជ្ជាជីវៈរបស់រដ្ឋ ឯកជន ឬ អង្គការនានា ត្រូវទទួលបណ្តុះបណ្តាលជនពិការឱ្យចូលសិក្សាដោយបង់ថ្លៃ តាមអត្រាកំណត់សមស្រប ឬ ដោយឥតបង់ថ្លៃ សម្រាប់ជនពិការក្រីក្រ ឬ ជាយោធិនពិការ ។

អត្រានេះ ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីទទួលបន្ទុកវិស័យសង្គមកិច្ច និងរដ្ឋមន្ត្រីទទួលបន្ទុកវិស័យបណ្តុះបណ្តាលវិជ្ជាជីវៈ ។

មាត្រា ៤០.–

គ្រឹះស្ថានអប់រំ បណ្តុះបណ្តាល បច្ចេកទេស និងវិជ្ជាជីវៈរបស់រដ្ឋ ឯកជន ឬ អង្គការនានា ត្រូវរៀបចំការសម្របសម្រួលសមស្របដល់ជនពិការ ដែលជាបេក្ខជនដាក់ពាក្យសុំចូលសិក្សា ឬ ជាសិក្ខាកាម ឬ ជាកម្មសិក្សាការី លើកលែងតែក្នុងករណីការសម្របសម្រួលនោះ មានបន្ទុកធ្ងន់ធ្ងរហួសហេតុ ។

មាត្រា ៤១.–

គ្រឹះស្ថានអប់រំ បណ្តុះបណ្តាល បច្ចេកទេស និងវិជ្ជាជីវៈរបស់រដ្ឋ ឯកជន ឬ អង្គការនានា ត្រូវរៀបចំកម្មវិធីបណ្តុះបណ្តាលលំអិតជាលាយលក្ខណ៍អក្សរ រួចប្រកាសផ្សាយឱ្យជន

ពិការបានដឹងជាមុន ។ កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈនេះ ត្រូវធ្វើជូនស្ថាប័នមានសមត្ថកិច្ច ដើម្បីជានាការអនុវត្តឱ្យបានត្រឹមត្រូវ ។

ជំពូកទី ៨
ការលើកទឹកចិត្ត

មាត្រា ៤២.-

រដ្ឋត្រូវលើកទឹកចិត្តដល់ជនពិការ ដែលប្រកបមុខរបរ អាជីវកម្ម សិប្បកម្មជាលក្ខណៈឯកត្តជន ឬ គ្រួសារ ឬ សមូហភាពរបស់ជនពិការ តាមរយៈការកាត់បន្ថយពន្ធដារ និងការផ្តល់អាទិភាពផ្សេងៗទៀត ស្របតាមច្បាប់ជាធរមាន ។

មាត្រា ៤៣.-

រដ្ឋត្រូវលើកទឹកចិត្តផ្នែកពន្ធដារ និងលើកទឹកចិត្តផ្សេងៗទៀត ស្របតាមច្បាប់ជាធរមាន ដល់និយោជក គ្រឹះស្ថានសិក្សា គ្រឹះស្ថានអប់រំ បណ្តុះបណ្តាល បច្ចេកទេស និងវិជ្ជាជីវៈដែលបានទទួលជនពិការឱ្យចូលធ្វើការអប់រំ បណ្តុះបណ្តាល ទៅតាមអត្រាកំណត់សមស្រប ឬលើសអត្រាកំណត់សមស្រប ដែលមានចែងក្នុងជំពូកទី ៧ នៃច្បាប់នេះ ។

ជំពូកទី ៩
ការបោះឆ្នោត

មាត្រា ៤៤.-

ជនពិការគ្រប់រូប មានសិទ្ធិចូលរួមក្នុងការបោះឆ្នោត ឬ ឈរឈ្មោះជាបេក្ខជនឱ្យគេបោះឆ្នោត ស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពីការបោះឆ្នោតជាធរមាន ។

មាត្រា ៤៥.-

ការប្រមាថ ការរើសអើង ចំពោះពិការភាពរបស់បេក្ខជន ត្រូវហាមឃាត់ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ជំពូកទី ១០
មូលនិធិជនពិការ

មាត្រា ៤៦.-

ត្រូវបង្កើតមូលនិធិជនពិការ ជាគ្រឹះស្ថានរដ្ឋបាលសាធារណៈ ក្នុងគោលបំណងដូចតទៅ :

១-ផ្តល់មូលនិធិសម្រាប់ការអនុវត្តគម្រោងកម្មវិធីផ្សេងៗ ដែលជួយដល់ជនពិការ និងគាំទ្រដល់ស្ថាប័ន គ្រឹះស្ថាននានា ដែលផ្តល់សេវាកម្មដល់ជនពិការ ដូចជាផ្នែកសុខាភិបាល ស្តារលទ្ធភាពពលកម្ម អប់រំបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ និងការរកការងារឱ្យធ្វើ ។

២-លើកកម្ពស់ និងបង្កើនសុខុមាលភាពរបស់ជនពិការ ជាពិសេស :

-ជនពិការក្រីក្រ និងយោធិនពិការ ដែលមិនបានទទួលសេវាស្តារលទ្ធភាពពលកម្ម

-គ្រួសារជនពិការក្រីក្រ និងយោធិនពិការ ដែលពឹងផ្អែកលើជនពិការក្នុងជីវភាពរស់នៅ

-ជនពិការក្រីក្រ និងយោធិនពិការ ដែលបានទទួលសេវាស្តារលទ្ធភាពពលកម្ម ឬ ជនពិការ ដែលមានជំនាញតែពុំទាន់ទទួលបានការងារធ្វើ ។

៣-ផ្តល់ប្រាក់កម្ចីសម្រាប់ការសម្របសម្រួលសមស្រប ។

មាត្រា ៤៧.-

ការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិជនពិការ ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ៤៨.-

មូលនិធិជនពិការ មានប្រភពចំណូលមកពីការឧបត្ថម្ភ និងអំណោយរបស់រាជរដ្ឋាភិបាល ស្ថាប័ន គ្រឹះស្ថាន អង្គការជាតិ អង្គការអន្តរជាតិ សប្បុរសជននានា គ្រប់មជ្ឈដ្ឋាន និងភាគទាន ដែលមានចែងក្នុងមាត្រា ៣៧ នៃច្បាប់នេះ ។

ជំពូកទី ១១
ការអនុវត្តសន្ធិសញ្ញាអន្តរជាតិ

មាត្រា ៤៩.-

បទប្បញ្ញត្តិទាំងឡាយនៃសន្ធិសញ្ញាអន្តរជាតិទាក់ទងនឹងច្បាប់ស្តីពីកិច្ចការពារ និង លើកកម្ពស់សិទ្ធិជនពិការ ដែលព្រះរាជាណាចក្រកម្ពុជាជាភាគី ត្រូវយកមកអនុវត្តជាមួយ ច្បាប់នេះ ។

ក្នុងករណីមានទំនាស់ជាមួយនឹងបទប្បញ្ញត្តិទាំងឡាយនៃច្បាប់នេះ បទប្បញ្ញត្តិនៃសន្ធិ-សញ្ញាអន្តរជាតិទាំងនោះ ត្រូវចាត់ទុកជាបទប្បញ្ញត្តិគោល ។

ជំពូកទី ១២
ទោសប្បញ្ញត្តិ

មាត្រា ៥០.-

អំពើប៉ះពាល់ដល់ការប្រើប្រាស់ដោយសេរីនូវសិទ្ធិបោះឆ្នោត ឬ ដល់និយ័តភាពនៃការ បោះឆ្នោតរបស់ជនពិការ ដោយប្រើហិង្សា ការបង្ខិតបង្ខំ ការគំរាមកំហែង ឬ ឧបាយកល ទុច្ចរិត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

បទល្មើសនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និង ពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ប្រសិន បើបទល្មើសនេះបានប្រព្រឹត្តដោយមានការប្រើអាវុធ ។

មាត្រា ៥១.-

អំពើរបស់បុគ្គល ដែលមានកាតព្វកិច្ចថែរក្សា ដែលបោះបង់ជនពិការដោយចេតនា អមនុស្សធម៌ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជា

ប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ប្រសិនបើអំពើបោះបង់បណ្ដាលឱ្យអន្ដរាយដល់សុខភាព ឬ សន្ដិសុខរបស់ជនពិការ ។

មាត្រា ៥២.-

អំពើរបស់ជនគ្រប់រូប ដែលមានអំណាចទៅលើជនពិការ ដែលបង្អត់អាហារ ឬ គ្មានការថែទាំរហូតដល់ខូចសុខភាពជនពិការនោះ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

មាត្រា ៥៣.-

អំពើទាញយកប្រយោជន៍ដោយចេតនា ដោយរំលោភលើភាពល្ងង់ខ្លៅ ឬ ភាពទន់ខ្សោយនៃបុគ្គលនេះ បណ្ដាលមកពីស្ថានភាពពិការភាព ដោយបង្ខំបុគ្គលនេះឱ្យប្រព្រឹត្តអំពើ ឬ មិនប្រព្រឹត្តអំពើ ដែលធ្វើឱ្យខូចប្រយោជន៍យ៉ាងធ្ងន់ធ្ងររបស់បុគ្គលនេះ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

មាត្រា ៥៤.-

ត្រូវពិន័យអន្ដរការណ៍ជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១.០០០.០០០ (មួយលាន) រៀល ចំពោះនីតិបុគ្គលដែលមិនព្រមបង់ចូលហិបមូលនិធិជនពិការ ដូចមានកំណត់នៅក្នុងមាត្រា ៣៧ នៃច្បាប់នេះ ដោយគ្មានមូលហេតុសមស្រប ។

ត្រូវពិន័យអន្ដរការណ៍ជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១.០០០.០០០ (មួយលាន) រៀល ចំពោះប្រធានស្ថាប័នរដ្ឋដែលមិនព្រមអនុវត្តមាត្រា ៣៥ នៃច្បាប់នេះ ដោយគ្មានមូលហេតុសមស្រប ។

ការពិន័យអន្ដរការណ៍ជាសមត្ថកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

មាត្រា ៥៥.-

ការក្លែងបន្លំប័ណ្ណសម្គាល់យានយន្ដ ឬ ប័ណ្ណបើកបរពិសេសសម្រាប់ជនពិការ ឬ អំពើប្រព្រឹត្តដោយទុច្ចរិត ដើម្បីទទួលបានសិទ្ធិ និងអាទិភាពដូចមានចែងក្នុងមាត្រា ២៥ នៃច្បាប់

នេះ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និង ពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

មាត្រា ៥៦.-

ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល អំពើជ្រៀតជ្រែកដោយខុសច្បាប់ ទៅក្នុងការអនុវត្តមុខងារសាធារណៈណាមួយ ដោយបំពេញកិច្ចណាមួយក្នុងចំណោមកិច្ចទាំងឡាយ ដែលសម្រាប់តែអ្នកមានសិទ្ធិក្នុងមុខងារនេះ ។

ជំពូកទី ១៣

អន្តរប្បញ្ញត្តិ

មាត្រា ៥៧.-

ទីកន្លែងសាធារណៈទាំងឡាយណា ដែលបានសាងសង់ មុនច្បាប់នេះចូលជាធរមាន ហើយដែលមានលទ្ធភាព ត្រូវរៀបចំកែសម្រួលទីកន្លែងសាធារណៈនោះ យ៉ាងយូររយៈពេល ៥ (ប្រាំ) ឆ្នាំ ដើម្បីឱ្យជនពិការមានលក្ខណៈងាយស្រួលចេញ-ចូលបាន ។

ក្នុងករណីមិនគោរពតាមវាក្យខ័ណ្ឌខាងលើ ត្រូវផ្ដន្ទាទោសពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១.០០០.០០០ (មួយលាន) រៀល ។

មាត្រា ៥៨.-

ទីកន្លែងសាធារណៈទាំងឡាយណា ដែលបានសាងសង់មុនច្បាប់នេះចូលជាធរមាន ហើយមិនទាន់បានរៀបចំ ដូចមានចែងក្នុងមាត្រា ២៦ នៃច្បាប់នេះ ហើយដែលមានលទ្ធភាព ត្រូវរៀបចំកែសម្រួលទីកន្លែងសាធារណៈនោះ យ៉ាងយូររយៈពេល ៥ (ប្រាំ) ឆ្នាំ ។

ក្នុងករណីមិនគោរពតាមវាក្យខ័ណ្ឌខាងលើ ត្រូវផ្ដន្ទាទោសពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១.០០០.០០០ (មួយលាន)រៀល ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

មាត្រា ៥៩.-

ក្រសួង ស្ថាប័នរដ្ឋ និងនីតិបុគ្គល ដែលជ្រើសរើសបុគ្គលិកចូលបម្រើការងារ ដូចមានចែងក្នុងមាត្រា ៣៤ និងមាត្រា ៣៥ នៃច្បាប់នេះ ត្រូវចាប់អនុវត្តក្នុងរយៈពេល១(មួយ) ឆ្នាំ ក្រោយច្បាប់នេះចូលជាធរមាន ។

ជំពូកទី ១៤

អវសានប្បញ្ញត្តិ

មាត្រា ៦០.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០០៩

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

៣រល.០៩០៧. ៧ម្ភ១

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន,

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

ហត្ថលេខា

អ៊ិត សំហេង

លេខ : ៦៦៥ ច.ល

ថតចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ២០០៩

អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល

ស៊ុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៦០៩/៦៤៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្សតខត្តិយា ខេមរជាតិ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រ្តីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ក/ គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់ "មហាសេរីវឌ្ឍន៍" ចំពោះ :

១- ឯកឧត្តម ពេជ្រ គីមស្រ៊ាង
២- ឯកឧត្តម ហាក់ ប៊ុនធឿន
៣- ឯកឧត្តម ចាន់ សុខុន្ឋ
៤- លោកឧកញ៉ា ហាន់ យឿង
៥- លោក ម៉ាត់ សាវុធ

ខ/ គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ "មហាសេរីវឌ្ឍន៍" ចំពោះ :

១- ឯកឧត្តម ឧកញ៉ា ឡេង ប៊ុនតេង

គ/ គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់ "មហាសេនា" ចំពោះ :

១- ឯកឧត្តម ទឹម ប៊ុណ្ណា
២- ឯកឧត្តម ជា ឆា

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL ·

៣- ឯកឧត្តម ថាច់ វណ្ណៈ

៤- ឯកឧត្តម សួង ចាន់ថន

៥- ឯកឧត្តម ឈឹម សៅគី

៦- ឯកឧត្តម ស៊ឹម គីមសាន

៧- ឯកឧត្តម ម៉ៅ សុវត្ថារា

៨- ឯកឧត្តម ស្រេង វាសនា

៩- លោកឧកញ៉ាសួន វណ្ណឌី

១០- ឯកឧត្តម ចៅ សុធី

១១- លោក តេង សឿន

១២- លោក ហុង ពៅ

១៣- លោក ស៊ឹម សុផង់

១៤- លោក ជុំ វង

១៥- លោក មួង វិបុល

១៦- លោក កែវ ធី

១៧- លោក អោ វឌ្ឍមុនី

១៨- លោក ជុំ វណ្ណី

ឃ / គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ "មហាសេនា" ចំពោះ :

១- លោក អ៊ុន ឃឹម

ង / គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់ "ធិបឌិន្ទ" ចំពោះ :

១- លោក សួស សុខុន

២- លោក អ៊ឹង ទីរៈ

៣- លោក មាស វណ្ណា

៤- លោក កាយ សុខហៃ

៥- លោក យេល លក្ខិណា



៦- លោក នួន សុគន្ធ

៧- លោក ជ មានហុក

៨- លោក ពេជ សារឿន

៩- លោក អំ ប៊ុនលី

១០- លោកស្រី លី វណ្ណារី

១១- លោក គាត ហ៊ុល

១២- លោកស្រី នាង សុវណ្ណា

ច / គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់ "សេនា" ចំពោះ :

១- ឯកឧត្តម ជិន សាវុធ

២- លោក សែន វ៉ាន់ណាក់

៣- លោក យឿម ម៉ាន់

ឆ / គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់ "អស្សឫទ្ធិ" ចំពោះ :

១- លោក នៅ វៃ

២- លោក គង់ សុខូ

៣- លោក យន់ សាវៃ

៤- លោក ម៉ី ចំរើន

៥- លោក ស្រ៊ុន សុភ័ក្ត្រ

៦- លោក ឈុប សម្បត្តិ

៧- លោក អ៊ូ សំណាង

៨- លោក ម៉េង ស៊ិន

៩- លោក សៅ តិរុណ

១០- លោក ម៉ុប គីមអាន

១១- លោក ជឿន ធួន

១២- លោក ចេង ធួក



១៣- លោក ចាន់ សុគៀន

១៤- លោក តាន់ សុខារិទ្ធ

១៥- លោក ម៉ាន់ កុសិមា

១៦- លោក ឈរ ខាសនា

១៧- លោក ច័ក ចាន់ថន

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

៣រក.០៦០៦.៦៥៥

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០០៩

លេខ : ៧៣៣ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៩

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ស៊ុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៧០៩/៧២៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពី លក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៦៣ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តម្លើងថ្នាក់ក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រីនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលរបស់ក្រសួង ស្ថាប័ន គិតចាប់ពីថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០០៩ ដូចមានរាយនាមខាងក្រោម :

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល		
១- លោកឧត្តម សុភ មិន	ពីឧត្តមមន្ត្រី ថ្នាក់លេខ ២	ទៅឧត្តមមន្ត្រី ថ្នាក់លេខ ១

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

២	ឯកឧត្តម គង ច័ន្ទថា	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៣	ទៅឧត្តមមន្ត្រី ថ្នាក់លេខ ២
៣	ឯកឧត្តម តោគ សុវណ្ណរិទ្ធ	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៤	ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៣
ក្រសួងសុខាភិបាល			
៤	ឯកឧត្តម ម៉ម ប៊ុនហេង	ពីឧត្តមមន្ត្រី ថ្នាក់លេខ ២	ទៅឧត្តមមន្ត្រី ថ្នាក់លេខ ១
៥	ឯកឧត្តម លឹម ជារាមណី	ពីឧត្តមមន្ត្រី ថ្នាក់លេខ ២	ទៅឧត្តមមន្ត្រី ថ្នាក់លេខ ១
៦	ឯកឧត្តម អ៊ឹង តីរុន	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៥	ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៤
៧	ឯកឧត្តម ទេព លន់	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៥	ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៤
៨	ឯកឧត្តម អ៊ុំ សុផល	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦	ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៥
ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍			
៩	ឯកឧត្តម សារ៉ាក់ ខាន់	ពីឧត្តមមន្ត្រី ថ្នាក់លេខ ២	ទៅឧត្តមមន្ត្រី ថ្នាក់លេខ ១
១០	ឯកឧត្តម កុយ ពុំ	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៤	ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៣
១១	ឯកឧត្តម ព្រុំ សន្ធរ	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៤	ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៣
ក្រសួងព័ត៌មាន			
១២	ឯកឧត្តម ចាន់ គីមសា	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៣	ទៅឧត្តមមន្ត្រី ថ្នាក់លេខ ២
១៣	ឯកឧត្តម ប៊ុត បូទុត	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៣	ទៅឧត្តមមន្ត្រី ថ្នាក់លេខ ២
១៤	ឯកឧត្តម តន់ យ៉ាន	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៣	ទៅឧត្តមមន្ត្រី ថ្នាក់លេខ ២
១៥	ឯកឧត្តម ទី សារ៉ាន	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៣	ទៅឧត្តមមន្ត្រី ថ្នាក់លេខ ២
១៦	ឯកឧត្តម គីម គុណាវឌ្ឍន៍	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៤	ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៣
១៧	លោកជំទាវ នង បឿន	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៤	ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៣
រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ			
១៨	ឯកឧត្តម ថៅ សេដ្ឋាណា	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៣	ទៅឧត្តមមន្ត្រី ថ្នាក់លេខ ២

មាត្រា ២ : តម្លើងថ្នាក់ក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលតាមកម្រិតសញ្ញាប័ត្រ នៅ ទីស្តីការគណៈរដ្ឋមន្ត្រី ដូចមានរាយនាមខាងក្រោម :

១៩	ឯកឧត្តម ហូ វិចិត្រ	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៣	ទៅឧត្តមមន្ត្រី ថ្នាក់លេខ ២
២០	ឯកឧត្តម ប៊ូល ពីឌូ	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៣	ទៅឧត្តមមន្ត្រី ថ្នាក់លេខ ២
២១	ឯកឧត្តម ស៊ាន បូរ៉ាត	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៤	ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៣
២២	ឯកឧត្តម សេង ទៀង	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៤	ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៣
[illegible]	ឯកឧត្តម សៀង កែវឡាយ	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៤	ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៣
[illegible]	ឯកឧត្តម ឆាយ សារុធ	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៤	ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៣
២៥	ឯកឧត្តម ឈរ ថាវណាត	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៤	ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៣

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

២៦	ឯកឧត្តម ម៉ែន ស៊ន	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៥	ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៤

មាត្រា ៣ : តម្លើងថ្នាក់ក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រីនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលរបស់ក្រសួង ស្ថាប័ន គិតចាប់ពីថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០០៩ ដូចមានរាយនាមខាងក្រោម :

ក្រសួងព្រះបរមរាជវាំង			
២៧	ឯកឧត្តម សូ ស៊ីនួន	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦	ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៥
២៨	ឯកឧត្តម នូ ឌុម	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦	ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៥
២៩	ឯកឧត្តម ផេង តិរុណ	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦	ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៥
៣០	ឯកឧត្តម គីម សឿ	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦	ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៥
៣១	ឯកឧត្តម ឡាក់ គី	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦	ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៥
៣២	ឯកឧត្តម មាស អ៊ែន	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦	ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៥
៣៣	លោកជំទាវ តាន់ សុខា	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦	ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៥
៣៤	ឯកឧត្តម ទ៉ាន់ ទ៉ាន	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦	ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៥
៣៥	ឯកឧត្តម មូល សារឿន	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦	ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៥
ក្រសួងពាណិជ្ជកម្ម			
៣៦	ឯកឧត្តម គីម ស៊ីថន	ពីឧត្តមមន្ត្រី ថ្នាក់លេខ ២	ទៅឧត្តមមន្ត្រី ថ្នាក់លេខ ១
៣៧	ឯកឧត្តម ឈួន ដារ៉ា	ពីឧត្តមមន្ត្រី ថ្នាក់លេខ ៦	ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៥

មាត្រា ៤ : មន្ត្រីដែលត្រូវបានតម្លើងថ្នាក់ដូចមានឈ្មោះក្នុងមាត្រា ២ ខាងលើត្រូវរក្សាទុកអតីតភាពសម្រាប់ឡើងថ្នាក់តាមវេនជ្រើសរើស និងវេនអតីតភាពជំដែល ។

មាត្រា ៥ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៦ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៧ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣រល.០៩០៧.៧៣៧

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០៩

លេខ: ៦៨៧ ច.ល

ជំរាបជូនចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ២០០៩

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៧០៩/៧៤៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ជូនចំពោះ :

១-លោក អ៊ិច សារុ
២-លោក ឡៅ ម៉ុនឆៃ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ ជូនចំពោះ :

១- លោក តាត់ សុហ៊ុម
២- លោក កើត សុធា
៣- លោក ម៉ី មគ្គ
៤- លោក អៀង ខុង
៥-លោក ឃ្លោក នួយ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា ជូនចំពោះ :

១- លោក ចក់ ចិន្តា

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ ជូនចំពោះ :

១- លោក សួស ស៊ីយ៉ាត
២- លោក យឹម ឡាំង
៣-លោក មៀវ សារ៉ៃម៉េ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខ: ៦៦៦.ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

៣រល.០៩០៧.៧៣៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ. ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០៩

ព្រះរាជក្រឹត្យ

នស/រកត/០៧០៩/៧២៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ជូនចំពោះ :

១-លោក ជា តួងគិមៀ
២-លោក គង់ បៃ
៣-លោក យិន នូ

៣រល.០៩០៧.៧៤០

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០៩

លេខ: ៦៩៥.ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

យុន ឌិនកេន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាស្រុកស្នួល នៃខេត្តក្រចេះ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លេខ ១៣៧ គជប.សសរ ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ២០០៩ ស្តីពីបេក្ខជនជាប់ឆ្នោតក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានទទួលស្គាល់សមាសភាពក្រុមប្រឹក្សាស្រុកស្នួល នៃខេត្តក្រចេះ អាណត្តិទី១ ដូចមានរាយនាមខាងក្រោម :

១- លោក **ស៊ឺ ជួន** ជាប្រធានក្រុមប្រឹក្សាស្រុក

២- លោក ភុយ គាន ជាសមាជិកក្រុមប្រឹក្សាស្រុក

៣- លោក យឹម សិរិទ្ធ ជាសមាជិកក្រុមប្រឹក្សាស្រុក

៤- លោក ហួន ឈួន ជាសមាជិកក្រុមប្រឹក្សាស្រុក

៥- លោកស្រី ថោង សុវណ្ណារី ជាសមាជិកក្រុមប្រឹក្សាស្រុក

៦- លោក ព្រុំ ចាន់ដិច ជាសមាជិកក្រុមប្រឹក្សាស្រុក

៧- លោក ឡាយ ម៉ិនធឿន ជាសមាជិកក្រុមប្រឹក្សាស្រុក

៨- លោកស្រី ហោង ម៉ិច ជាសមាជិកក្រុមប្រឹក្សាស្រុក

៩- លោក គិន លេច ជាសមាជិកក្រុមប្រឹក្សាស្រុក

១០- លោក ញ៉ិប សាគុណ ជាសមាជិកក្រុមប្រឹក្សាស្រុក

១១- លោក អ៊ឹម ផន ជាសមាជិកក្រុមប្រឹក្សាស្រុក

១២- លោក អន ឆេងអ៊ីន់ ជាសមាជិកក្រុមប្រឹក្សាស្រុក

១៣- លោក សួស ឆិត្យ ជាសមាជិកក្រុមប្រឹក្សាស្រុក

១៤- លោក កែវ ចាន់ថុល ជាសមាជិកក្រុមប្រឹក្សាស្រុក

១៥- លោក ហាក់ ម៉ាត់ ជាសមាជិកក្រុមប្រឹក្សាស្រុក ។

មាត្រា ២ : ក្នុងករណីមានសមាជិកក្រុមប្រឹក្សាណាម្នាក់ បាត់បង់សមាជិកភាពពីក្រុមប្រឹក្សា ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃមាត្រា ២២ និងមាត្រា២៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

មាត្រា ៣ : ក្នុងការអនុវត្តការងារ ប្រធាន និងសមាជិកក្រុមប្រឹក្សាស្រុកស្នួល នៃខេត្តក្រចេះ ត្រូវអនុវត្តតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋាននានាជាធរមាន ។

មាត្រា ៤ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៥ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែ ឧសភា ឆ្នាំ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត*

(ដើម្បីជូនជ្រាប)

- *ដូចមាត្រា ៥*
- *ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ...៣៧៦.អនក្រ-តត

អនុក្រឹត្យ

ស្តីពី

ការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាស្រុកឆ្លូង នៃខេត្តក្រចេះ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
